# សេចក្តីថ្លែងការណ៍រួមរបស់សម្ព័ន្ធទន្លេកម្ពុជា
# ចំពោះបច្ចុប្បន្នភាពនៃទំនប់វារីអគ្គីសនីសេសានក្រោម២

យើងខ្ញុំជាសមាជិកសម្ព័ន្ធទន្លេកម្ពុជា ដែលមានរាយនាមដូចខាងក្រោម មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេចក្តីជូនដំណឹង ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៦ ដោយរដ្ឋបាលខេត្តស្ទឹងត្រែង ស្តីពី «**ការកំណត់ឱសានវាទនៃការងារស្រង់ស្ថិតិ ផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គីសនីសេសានក្រោម២**» ដោយកំណត់យក **ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៦** ដ៏ខ្លីខាងមុខនេះ ជាថ្ងៃបញ្ឈប់ការស្រង់ស្ថិតិចុងក្រោយ។

សេចក្តីជូនដំណឹងនេះ ធ្វើឱ្យយើងខ្ញុំមានក្តីព្រួយបារម្ភកាន់តែខ្លាំងថា៖ គម្រោងទំនប់វារីអគ្គីសនីសេសានក្រោម២នេះ មិនបានអភិវឌ្ឍប្រកបដោយការធានានូវនិរន្តភាព និងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាដោយពិតប្រាកដឡើយ ជាពិសេសសហគមន៍មូលដ្ឋានដែលកំពុងរងផលប៉ះពាល់។ ដោយហេតុថាបញ្ហាប្រឈមជាច្រើនមិនទាន់បានដោះស្រាយ ទាក់ទងនឹងដំណើរការសំណង និងការផ្លាស់ប្តូរលំនៅឋានថ្មី ហើយរដ្ឋបាលខេត្តកំណត់ពេលវេលាមិនសមរម្យ និងជម្រុញការអនុវត្តដោយដាក់ឱសានវាទ ជាកត្តាប្រឈមកាន់តែខ្លាំងជាមួយប្រជាពលរដ្ឋ និងផ្ទុយពីស្មារតីច្បាប់ជាតិ និងបទដ្ឋានគតិយុត្តក្រោមច្បាប់មួយចំនួន ដែលពាក់ព័ន្ធទៅនឹងការចូលរួមជាសារធារណៈពេញលេញ[1] ព្រមទាំងកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា[2]។

ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គីសនីសេសានក្រោម២ ទាំងអស់មានសិទ្ធិទទួលបានដំណើរការមួយដែលយុត្តិធម៌ មានតម្លាភាព និងមានការរួមបញ្ចូល ដែលអាចប្រាកដថាទទួលបានសំណង "**សមរម្យ និងយុត្តិធម៌**" ព្រមទាំងធានាថាប្រជាពលរដ្ឋនឹងស្ថិតនៅក្នុងស្ថានភាពធម្មតាឬប្រសើរឡើង ក្រោយការផ្លាស់ប្តូរលំនៅឋានថ្មី។ សហគមន៍ជនជាតិដើមភាគតិច និងអ្នកប៉ះពាល់ផ្សេងៗទៀត មានសិទ្ធិទទួលបានឱកាស "**ធ្វើការសម្រេចចិត្តដោយមានការជូនដំណឹងជាមុន ទទួលបានព័ត៌មានគ្រប់គ្រាន់ និងដោយសេរី** (Free Prior and Informed Consent)" ចំពោះគម្រោងផែនការផ្សេងៗ ដែលនឹងផ្លាស់ប្តូរពួកគាត់ចេញពីដីធ្លី និងធនធានធម្មជាតិរបស់ពួកគាត់។

យោងតាមការស្រាវជ្រាវរបស់សហគមន៍[3] បង្ហាញថាមិនមានព័ត៌មានគ្រប់គ្រាន់ត្រូវបានផ្តល់ឱ្យអ្នកភូមិអំពីគោលបំណងនៃការចុះស្រង់ស្ថិតិ ដំណើរការទូទាត់សំណង និងការផ្លាស់ប្តូរលំនៅឋានថ្មី ក្នុងកំឡុងពេលធ្វើការចុះស្រង់ស្ថិតិទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋប៉ះពាល់ ក្នុងចន្លោះ (ចុងឆ្នាំ២០១៤ និងដើមឆ្នាំ២០១៥)។ ជាលទ្ធផលប្រជា

---

[1] រដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា ៣៥ និង៤៤) ច្បាប់ភូមិបាលឆ្នាំ២០០១ (មាត្រា ៤ និង៥) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ១៩៩៦ (មាត្រា ១៦) មគ្គុទ្ទេសក៏នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ស្តីពីការចូលរួមជាសារណៈ (ទំព័រទ១៧)។

[2] កាតិកៈសញ្ញាស្តីពី សិទ្ធិឯកជននិងនយោបាយ ឆ្នាំ១៩៦៦ កាតិកៈសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ឆ្នាំ១៩៦៦ សេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចឆ្នាំ២០០៧។ សេចក្តីណែនាំសម្រាប់ ស្តង់ដាសិទ្ធិមនុស្សនៅក្នុងការអភិវឌ្ឍដែលបង្ករឱ្យមានការរុះរើទីលំនៅ ត្រូវបានបង្កើតឡើងនៅក្នុងអង្គការសហប្រជាជាតិ "គោលការណ៍ច្បាប់ជាមូលដ្ឋាន និងសេចក្តីណែនាំចំពោះការអភិវឌ្ឍទាក់ទងនឹងការ បណ្តេញចេញនិងការប្តូរទីលំនៅ ឆ្នាំ១៩៩៧"។

[3] បញ្ជីសំណួរជាង ២២០ ត្រូវបានបំពេញនៅក្នុងភូមិក្បាលរមាស ស្រែស្រណុក ច្រប់ ស្រែគរ ១ និង ២ នៅកំឡុងខែ កក្កដា និង សីហា ឆ្នាំ២០១៥។ ការសម្ភាសន៏ស៊ីជម្រៅក៏ត្រូវបានធ្វើឡើងរួមជាមួយប្រជាពលរដ្ឋនៅភូមិភ្លុក ដែលបានបាត់បង់ដីដោយសារគម្រោងវារីអគ្គីសនីសេសានក្រោម២ ប៉ុន្តែមិនត្រូវបានរាប់បញ្ចូលក្នុងការស្រង់ស្ថិតិទ្រព្យសម្បត្តិឡើយ។

ពលរដ្ឋជាច្រើនមិនយល់ពីដំណើរការ និងឯកសារនៃការចុះស្រង់ស្ថិតិទាំងនោះឡើយ។ អ្នកភូមិបានរាយការណ៍ថា ការពិគ្រោះយោបល់នៅមានកំរិត ក៏ដូចជាការផ្ដល់ឱកាសដើម្បីសួរសំណួរ ហើយពួកគាត់មិនត្រូវបានផ្ដល់ឱ្យនូវឯកសារថតចម្លងនៃការស្រង់ស្ថិតិនោះឡើយ។ ប្រជាពលរដ្ឋជាច្រើន ប្រឈមនឹងការគម្រាមកំហែង គៀបសង្កត់ និងទទួលរងនូវសម្ពាធក្នុងកំឡុងពេលស្រង់ស្ថិតិទ្រព្យសម្បត្តិនោះ។ ដោយឡែកប្រជាពលរដ្ឋប៉ះពាល់មួយចំនួនដែលបានចូលរួម ទោះត្រូវបានជូនដំណឹងឬក៏មិនបាន ពួកគាត់មានតែព្រមទទួលព្រោះគ្មានជម្រើស[4]។ របាយកាណ៍ទាំងនេះ លើកឡើង ពីសំណួរសំខាន់ៗ អំពីថាតើដំណើរការស្រង់ស្ថិតិនេះ ត្រូវបានប្រព្រឹត្តទៅដោយមានការអនុលោមទៅតាមច្បាប់កម្ពុជា ដែលបានអះអាងថា៖ ការរៀបចំកិច្ចសន្យាទាំងឡាយណាដែលមិនបានកើតចេញមកពីការព្រមព្រៀងដោយសេរី និងពិតប្រាកដ ពាក់ព័ន្ធនឹងព័ត៌មានមិនត្រឹមត្រូវ ឬមានការប្រើប្រាស់ការបង្ខិតបង្ខំ ឬគ្មានការពន្យល់ត្រឹមត្រូវដើម្បីទទួលបានកិច្ចព្រមព្រៀង គួរតែចាត់ទុកថាមិនស្របច្បាប់[5]។

ក្នុងករណីនេះ មានគ្រួសារជាច្រើនបន្តជំទាស់ក្នុងការចាកចេញពីដីរបស់ពួកគាត់ និងមិនទទួលយកគោលការណ៍សំណង និងការតាំងទីលំនៅថ្មី។ ពួកគាត់បានអះអាងថា ពួកគាត់មិនចង់ចាកចេញពីដីបុព្វបុរស និងទីតាំងជំនឿរបស់ពួកគាត់ ឬមិនព្រមបាត់បង់លទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ដែលធ្វើអោយជីវភាព និងវប្បធម៌របស់ពួកគាត់បិតបេរគង់វង្ស។ អ្នកភូមិដែលបានចូលរួមក្នុងការស្រង់ស្ថិតិទ្រព្យសម្បត្តិនេះ ឬបានទទួលសំណង បានបង្ហាញពីក្ដីបារម្ភ អំពីគុណភាពផ្ទះ ដីស្រែ នៅទីតាំងលំនៅឋានថ្មី បរិមាណនៃការទូទាត់សំណងដែលបានផ្ដល់ឱ្យ ព្រមទាំងការវាស់វែងដែលកំពុងអនុវត្ត ដើម្បីគាំទ្រដល់កម្មវិធីផ្លាស់ប្ដូរជីវភាពជាដើម។ អ្នកភូមិជាច្រើនដែលប្រឈមនឹងការបាត់បង់ដី និងលទ្ធភាពទទួលបានធនធានធម្មជាតិ ឬត្រូវទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរនោះ មិនត្រូវបានរាប់បញ្ចូលនៅក្នុងគោលនយោបាយសំណង និងការរើលំនៅដ្ឋានថ្មីឡើយ ហើយមិនត្រូវបានផ្ដល់អោយនូវការសងជម្ងឺចិត្តណាមួយឡើយ។ នេះរាប់ទាំងមនុស្សរាប់ពាន់នាក់នៅផ្នែកខាងលើ និងខាងក្រោមទីតាំងទំនប់ ព្រមទាំងអ្នកដែលរស់នៅតាមដងទន្លេមេគង្គ និងទន្លេសាប ដែលជួបប្រទះកត្តាគម្រាមកំហែងជាសារវ័ន្តទៅលើជីវភាព និងសុវត្ថិភាពស្បៀងអាហារផងដែរ ដោយសារការបាត់បង់ការនេសាទ ប្រភេទត្រីដែលបំលាស់ទី និងភក់ល្បាប់មានជីវជាតិសម្រាប់ដំណាំកសិកម្ម ដោយសារគម្រោងវារីអគ្គិសនីសេសានក្រោម២នេះ[6]។

ក្ដីបារម្ភទាំងនេះចោទជាសំណួរអំពីកាតព្វកិច្ចផ្លូវច្បាប់ចំពោះស្ដង់ដារជាតិ និងអន្តរជាតិ សម្រាប់ការទូទាត់សំណង និងការរុះរើលំនៅឋាន រួមទាំងកិច្ចការពារសិទ្ធិមនុស្សជាមូលដ្ឋាន ព្រមទាំងសិទ្ធិរបស់ជនជាតិដើមភាគតិចនៅក្នុងដំណើរការរុះរើលំនៅដ្ឋានរបស់ពួកគាត់។ តម្រូវការនានាដែលស្ថិតក្រោមគោលការណ៍ច្បាប់អន្តរជាតិសម្រាប់ការទូទាត់សំណង និងការរុះរើលំនៅឋាន ត្រូវបានគូសបញ្ជាក់ដោយតំណាងពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមនុស្សនៅកម្ពុជាគឺ **លោកស្រីរ៉ូណា ស្មីត** បន្ទាប់ពីដំណើរទស្សនៈកិច្ចរបស់លោកស្រី ទៅកាន់តំបន់ទំនប់វារីអគ្គីសនីសេសានក្រោម២នោះ[7]។

---

[4] សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជនផល (FACT), អង្គការភូមិខ្ញុំ (MVi); បណ្ដាញការពារទន្លេ៣ (3SPN), 'បទពិសោធរបស់សហគមន៍ដែល ត្រូវផ្លាស់ប្ដូរទីលំនៅសម្រាប់ទំនប់សេសានក្រោម២៖ របកគំហើញ និងអនុសាសន៍ ទៅលើសម្រង់ស្ថិតិទ្រព្យសម្បត្តិ' មេសា ២០១៦។

[5] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ផ្នែកទី២ មាត្រា ៣៤៥-៣៥០

[6] ការវិភាគឯករាជ្យបានសន្មត់ថា នឹងមានការបាត់បង់ជីវម៉ាស់របស់ត្រីចំនួន៩.៣%នៅទូទាំងអាងទន្លេមេគង្គ (Ziv et al 2010)។ ការស្រាវជ្រាវនេះក៏បានបង្ហាញផងដែរនូវការថយចុះនូវបរិមាណភក់ល្បាប់មានជីវជាតិចំនួន ៦-៨%។

[7] សេចក្ដីថ្លែងការណ៍បញ្ចប់បេសកម្មៈ សេចក្ដីថ្លែងការណ៍របស់សាស្ត្រាចារ្យ រ៉ូណា ស្មីត តំណាងពិសេសអង្គការសហប្រជាជាតិ ស្ដីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ភ្នំពេញ។

ការដាក់ឱសានវាទសម្រាប់ការចចារសំណង និងការរុះរើលំនៅឋាន នឹងធ្វើអោយសាធារណៈយល់ឃើញថា៖ ប្រជាពលរដ្ឋកាន់តែរងសម្ពាធ និងការគម្រាមកំហែង ដែលមិនមានប្រយោជន៍អ្វីដល់ភាគីទាំងពីឡើយ។ ដូច្នេះយើងខ្ញុំជាសមាជិកសម្ព័ន្ធទន្លេកម្ពុជា **សូមសំណូមពរឱ្យរាជរដ្ឋាភិបាល និងក្រុមហ៊ុនអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម ២** ពិចារណានូវក្តីព្រួយបារម្ភរបស់ប្រជាពលរដ្ឋគ្រប់រូប ដែលប៉ះពាល់ដោយគម្រោងសេសានក្រោម២នេះ ហើយបង្កលក្ខណៈឱ្យពួកគាត់បានទទួលបាននូវការដោះស្រាយដោយពេញលេញ តាមរយៈកិច្ចសន្ទនាមួយប្រកបដោយអត្ថន័យនិងមានតម្លាភាព មុនពេលដំណើរការរុះរើលំនៅដ្ឋាន និងការទូទាត់សំណងអាចបន្ត។ មួយវិញទៀត រាជរដ្ឋាភិបាលត្រូវតែបង្កើតអោយមានយន្តការបណ្តឹងដ៏មានប្រសិទ្ធិភាព និងអាចពឹងពាក់បានជាសាធារណៈមួយ ដែលមានគណៈកម្មការផ្លាស់ប្តូរទីលំនៅឋានដ៏ឯករាជ្យ និងមានការពិនិត្យតាមដានជាប្រចាំផងដែរ។

ជាថ្មីម្តងទៀតយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា៖ រាជរដ្ឋាភិបាល និងក្រុមហ៊ុននៅតែបន្តការចរចារ និងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការដោះស្រាយបញ្ហា ដើម្បីប្រាកដថាទំនប់សេសានក្រោម២ មានការអភិវឌ្ឍដោយតម្លាភាព មានការចូលរួមពេញលេញ ដើម្បីឈានទៅរកការអភិវឌ្ឍប្រកបដោយនិរន្តភាព ហើយអាចផ្តល់អត្ថប្រយោជន៍ពិតប្រាកដដល់ប្រជាពលរដ្ឋមូលដ្ឋានដែលកំពុងរងផលប៉ះពាល់ដោយគម្រោង និងប្រជាពលរដ្ឋកម្ពុជាទាំងមូល។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៦

**សូមទំនាក់ទំនងព័ត៌មានបន្ថែម:**

- បណ្ឌិត តឹក វណ្ណារ៉ា តំណាងសម្ព័ន្ធទន្លេកម្ពុជា (០១២ ៧៩៣ ៤៨៩)

**គាំទ្រដោយ:**

- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum)
- អង្គការភូមិខ្ញុំ (MVi)
- បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង (3SPN)
- សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
- បណ្តាញអ្នកថែរក្សាទឹកបឹងទន្លេសាប
- សមាគមថែរក្សាបរិស្ថាន និងវប្បធ៌ម (CEPA)
- អង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន (NRD)
- មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធ៌ម (MPC)
- អង្គការអភិវឌ្ឍន៍សហគមន៍កម្ពុជា (CCD Kratie)
- សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)
- អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO)
- សមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច (IRAM)
- សម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា (CIPA)
- សមាគមខ្មែរលើ (HA)
- អង្គការកសិករខ្មែរសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កសិករ (KFCADO)
- អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ (NAS)